**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

លេខ ០៤៥/១៣ ក.ប/ប្រ.ក

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៣

# ប្រកាស

## ស្តីពី

## ការដាក់ឲ្យប្រើពាក្យគន្លឹះ

ក្នុងអនុក្រឹត្យលេខ១៩០ អនក្រ.បក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១
ស្តីពីការគ្រប់គ្រងលើការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស
តាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន

## រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី២៥ ខែកញ្ញា ឆ្នាំ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី

-បានឃើញព្រះរាជក្រមលេខ នស/រកម/០១០៥/០០៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-បានឃើញអនុក្រឹត្យលេខ៥២ អនក្រ.បក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០០៥ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

-បានឃើញអនុក្រឹត្យលេខ១៩០ អនក្រ.បក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងលើការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេសតាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន

-តាមការចាំបាច់របស់ក្រសួង

*អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទ:(០២៣)៨៨៤៣៧៥ និងទូរសារ :(០២៣)៨៨២៧៦៩*

# សម្រេច

**ប្រការ១**.-

ត្រូវបានដាក់ឲ្យប្រើពាក្យគន្លឹះនៅក្នុងអនុក្រឹត្យលេខ១៩០ អនក្រ.បក ចុះថ្ងៃទី១៧ ខែសីហា ឆ្នាំ២០១១ ស្តីពីការគ្រប់គ្រងលើការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស តាមរយៈទីភ្នាក់ងារជ្រើសរើសឯកជន ដូចមានឧបសម្ព័ន្ធជូនភ្ជាប់ ដើម្បីធានាការអនុវត្តអនុក្រឹត្យដោយឯកភាព និងប្រកបដោយប្រសិទ្ធភាព។

**ប្រការ២**.-

នាយកខុទ្ទកាល័យ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានការងារ អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ អគ្គាធិការនៃអគ្គាធិការដ្ឋាន អង្គភាពក្រោមចំណុះក្រសួង និងទីភ្នាក់ងារជ្រើសរើសឯកជន ត្រូវអនុវត្តប្រកាសនេះឲ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

**រដ្ឋមន្ត្រី**

**វង្ស សូត**

***កន្លែងទទួល*** :

*-ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី*
*-ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី*
*-ទីស្តីការគណៈរដ្ឋមន្ត្រី*
*-ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ*
*-ក្រសួងមហាផ្ទៃ*
*-ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*
*-គ្រប់សាលារាជធានី និងខេត្ត*
*" ដើម្បីជូនជ្រាប*
*-ដូចប្រការ១៣ " ដើម្បីអនុវត្ត*
*-ឯកសារ-កាលប្បវត្តិ*

## ឧបសម្ព័ន្ធ

## ប្រកាសលេខ០៤៥/១៣ ក.ប/ប្រក ចុះថ្ងៃទី១៧ ខែ ធ្នូ ឆ្នាំ២០១៣

## ស្ដីពីការដាក់ឲ្យប្រើពាក្យគន្លឹះ

១- **បេក្ខជនពលករទេសន្តរប្រវេសន៍:** សំដៅយកពលរដ្ឋខ្មែរទាំងពីរភេទដែលស្ថិតក្នុងលក្ខខណ្ឌណាមួយ ឬមួយចំនួនដូចខាងក្រោម:

-មានបំណង កំពុងស្វែងរកសេវារកការងារឲ្យធ្វើនៅបរទេស កំពុងស្វែងរកការងារ នៅបរទេសធ្វើ ដែលបានទទួលការប្រព្រឹត្តបែបណាមួយពីទីភ្នាក់ងារជ្រើសរើសឯកជន ភ្នាក់ងារជ្រើសរើស និងបុគ្គលិកប្រភេទណាមួយរបស់ទីភ្នាក់ងារជ្រើសរើសឯកជន រាប់ទាំងការប្រព្រឹត្ត ដែលផ្ដល់អត្ថប្រយោជន៍ និងការប្រព្រឹត្ត ដែលនាំឲ្យខូចប្រយោជន៍ នាំឲ្យគ្រោះថ្នាក់បែបណាមួយដល់អ្នកមានបំណង ឬកំពុងស្វែងរកសេវារកការងារឲ្យធ្វើនៅបរទេស។

-កំពុងដាក់ពាក្យសុំទៅធ្វើការងារប្រភេទណាមួយ នៅប្រទេសណាមួយក្រៅពីព្រះរាជាណាចក្រកម្ពុជា នៅក្នុងទីកន្លែងដែលបានកំណត់ជាផ្លូវការរបស់ទីភ្នាក់ងារជ្រើសរើសឯកជន។

-មានឯកសារត្រឹមត្រូវស្ដីពីការដាក់ពាក្យសុំរកការងារណាមួយធ្វើ នៅទីកន្លែងណាមួយដែលបានកំណត់ជាផ្លូវការរបស់ទីភ្នាក់ងារជ្រើសរើសឯកជន នៅប្រទេសណាមួយក្រៅពីព្រះរាជាណាចក្រកម្ពុជា។

-កំពុងទទួលសេវានៃការណែនាំតម្រង់ទិសមុនចេញដំណើរ ដែលរួមមាន ការណែនាំស្ដីពីលក្ខខណ្ឌការងារ និងរបៀបរបបធ្វើការងារដែលត្រូវធ្វើ របៀបរបបរស់នៅ ឬការបង្រៀនភាសា និងហ្វឹកហាត់ជំនាញជាដើម ដែលសេវាទាំងឡាយនេះត្រូវបានផ្ដល់ជូនដោយទីភ្នាក់ងារជ្រើសរើសឯកជននៅមុនពេលចេញដំណើរទៅធ្វើការនៅបរទេស។

-កំពុងស្ថិតនៅក្នុងដំណើរការនៃការរៀបចំបែបបទទេសន្តរប្រវេសន៍ការងារ ដែលរួមមានជាអាទិ៍ ការធ្វើឯកសារសម្គាល់អត្តសញ្ញាណ ការធ្វើលិខិតឆ្លងដែន ការពិនិត្យ និងរៀបចំធ្វើកិច្ចសន្យាសេវារកការងារធ្វើនៅបរទេស កិច្ចសន្យាការងារ។

២- **ពលករទេសន្តរប្រវេសន៍:** សំដៅយកពលរដ្ឋខ្មែរទាំងពីរភេទដែលមានអាយុចាប់ពី១៨ឆ្នាំឡើង និងត្រូវតាមការកំណត់របស់ប្រទេសទទួលពលករ ដែលស្ថិតក្នុងលក្ខខណ្ឌណាមួយ ឬមួយចំនួនដូចខាងក្រោម:

-បញ្ចប់ការអប់រំណែនាំតម្រង់ទិសមុនចេញដំណើរដោយជោគជ័យ ដោយមានសេចក្ដីបញ្ជាក់ទទួលស្គាល់ពីអគ្គនាយកដ្ឋានការងារនៃក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ។

-រៀបចំឯកសារទេសន្តរប្រវេសន៍ការងាររួចហើយ មានជាអាទិ៍ លិខិតឆ្លងដែន កិច្ចសន្យាសេវារកការងារធ្វើនៅបរទេស កិច្ចសន្យាការងារ ការអនុញ្ញាតឲ្យធ្វើការងារ ទិដ្ឋាការចូលទៅធ្វើការងារនៅប្រទេសទទួល សំបុត្រមធ្យោបាយធ្វើដំណើរ។

-កំពុងធ្វើដំណើរពីព្រះរាជាណាចក្រកម្ពុជាត្រង់ទៅប្រទេសទទួល ដើម្បីធ្វើការងារតាមកិច្ចសន្យា។

-ទៅដល់ប្រទេសទទួល ហើយកំពុងត្រូវបានដាក់ឲ្យធ្វើការងារតាមកិច្ចសន្យា។

-បាន និងកំពុងអនុវត្តកិច្ចសន្យាការងារនៅក្នុងប្រទេសទទួលពលករ។

-ស្ថិតនៅក្នុងនីតិវិធីដោះស្រាយវិវាទការងារជាមួយនិយោជក ស្ថិតនៅក្នុងដំណើរការនៃយន្តការណាមួយនៃរដ្ឋបាលការងារ ដូចជាការស្នើសុំការអនុញ្ញាតណាមួយពីនិយោជក ការតវ៉ាណាមួយជាមួយនិយោជក ស្ថិតនៅក្នុងស្ថានភាពណាមួយនៃដំណាក់កាលគេចចេញពីការងារដោយប្រការណាមួយ ដែលពលករយល់ថាប្រកបដោយគ្រោះថ្នាក់ ស្ថិតនៅក្នុងដំណើរការដោះស្រាយណាមួយរបស់និយោជកសម្រាប់ជាផលប្រយោជន៍របស់ពលករ ស្របទៅតាមនីតិវិធី និងច្បាប់ជាធរមាន។

-បញ្ចប់កិច្ចសន្យាការងារ ត្រូវបានបញ្ឈប់ លាឈប់ពីការងារដោយប្រការណាមួយ។

-ស្ថិតនៅក្នុងដំណើរការនៃការរៀបចំធ្វើមាតុភូមិនិវត្តន៍។

-ស្ថិតនៅក្នុងដំណើរការនៃការធ្វើមាតុភូមិនិវត្តន៍ និងទទួលលិខិតបញ្ជាក់អំពីការងារដែលបានអនុវត្តនៅបរទេសដែលចេញឲ្យដោយក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ។

៣- **កិច្ចសន្យាសេវារកការងារឲ្យធ្វើនៅបរទេស:** សំដៅយកកិច្ចសន្យាណាដែលមានលក្ខខណ្ឌដូចខាងក្រោម:

-ភាគីទីភ្នាក់ងារជ្រើសរើសឯកជនធានាជួយរកការងារសមរម្យជាក់លាក់ណាមួយនៅប្រទេសណាមួយក្រៅពីកម្ពុជា ជូនពលករធ្វើ។

-ក្នុងការធានារកការងារជូនបេក្ខជនពលករធ្វើ ទីភ្នាក់ងារជ្រើសរើសឯកជនត្រូវផ្តល់សេវារកការងារឲ្យធ្វើឲ្យបានពេញលេញ។

-ភាគីពលករយល់ព្រមដោយស្ម័គ្រចិត្តធ្វើការងារជាក់លាក់ណាមួយនៅប្រទេសណាមួយក្រៅពីកម្ពុជា ដែលភាគីទីភ្នាក់ងារជ្រើសរើសឯកជនជាអ្នកផ្តល់ឲ្យ។

-លក្ខខណ្ឌគោលសំខាន់ៗដែលមានចែងក្នុងកិច្ចសន្យាការងារ ត្រូវតែចែងឲ្យបានត្រឹមត្រូវនៅក្នុងកិច្ចសន្យាសេវារកការងារឲ្យធ្វើ។

-កិច្ចសន្យាសេវារកការងារឲ្យធ្វើនៅបរទេសត្រូវធ្វើឲ្យបានត្រឹមត្រូវទៅតាមលក្ខខណ្ឌទាំងឡាយដែលបានកំណត់នៅក្នុងបទដ្ឋានអប្បបរមានៃកិច្ចសន្យាសេវារកការងារឲ្យធ្វើ។

-កិច្ចសន្យាសេវារកការងារឲ្យធ្វើនៅបរទេសត្រូវធ្វើជាភាសាខ្មែរ ចំនួនបីច្បាប់ ដោយរក្សាទុកនៅសាម៉ីពលករមួយច្បាប់ ទីភ្នាក់ងារជ្រើសរើសឯកជនមួយច្បាប់ និងនៅនាយកដ្ឋានមុខរបរនិងហត្ថពលកម្មមួយច្បាប់។

៤- **សេវារកការងារឲ្យធ្វើ:** សំដៅយកការងារដែលមានលក្ខខណ្ឌដូចខាងក្រោមៈ

-ការណែនាំពលករឲ្យបានយល់ដឹងច្បាស់លាស់គ្រប់លក្ខខណ្ឌទាំងអស់នៃការងារ ដែលត្រូវធ្វើតាមកិច្ចសន្យា និងគ្រប់បទប្បញ្ញត្តិទាំងឡាយនៅក្នុងកិច្ចសន្យាការងារ និងកិច្ចសន្យាសេវារកការងារឲ្យធ្វើ នៅមុនពេលសម្រេចចិត្ត និងចុះហត្ថលេខាលើកិច្ចសន្យាទាំងពីរ។

-ការបង្រៀនភាសា ដែលត្រូវប្រើក្នុងរយៈពេលអនុវត្តកិច្ចសន្យាការងារ ដោយត្រូវធានាឲ្យបានថាពលករចេះភាសាគ្រប់គ្រាន់អាចប្រើប្រាស់នៅនឹងកន្លែងធ្វើការងារ ស្របទៅតាមការងារជាក់ស្តែងនីមួយៗ ដែលទីភ្នាក់ងារជ្រើសរើសឯកជនដាក់ឲ្យពលករធ្វើការ។

-ការបង្ហាត់បង្ហាញឲ្យចេះធ្វើការងារ ដែលកំណត់នៅក្នុងកិច្ចសន្យាការងារ ដោយត្រូវបង្រៀនឲ្យពលករចេះធ្វើកិច្ចការលម្អិតនានានៃដំណាក់កាលនីមួយៗ ក្នុងចំណោមដំណាក់កាលទាំងអស់នៃការងារណាមួយជាកំណត់ ដែលដាក់ឲ្យពលករធ្វើ។

-ការណែនាំអំពីវិន័យការងារ និងរបៀបរបបធ្វើការងារនៅក្នុងប្រទេសទទួល ដោយត្រូវណែនាំឲ្យពលករយល់ដឹង និងគោរពឲ្យបានត្រឹមត្រូវអំពីបទបញ្ជាផ្ទៃក្នុងកន្លែងធ្វើការ ដូចជាភាពស្មោះត្រង់ ការខិតខំធ្វើការ ការគោរពពេលម៉ោងធ្វើការ ការមិនរំខានអ្នកដទៃ ឬការមិនធ្វើឲ្យខូចខាតទ្រព្យសម្បត្តិអ្នកដទៃជាដើម។

-ការណែនាំអំពីការរស់នៅ និងគោរពច្បាប់នៃប្រទេសទទួលពលករ ដោយត្រូវណែនាំពលករឲ្យយល់ដឹង និងមិនធ្វើឲ្យប៉ះពាល់ ឬរំខានដល់សេចក្តីសុខខាងផ្លូវកាយ និងខាងស្មារតី របៀបរបបរស់នៅ ច្បាប់ទម្លាប់ និងប្រពៃណីរបស់ពលរដ្ឋក្នុងមូលដ្ឋាន ដែលពលករស្នាក់នៅ និងធ្វើការងារ ឬទីណាដែលពលករទៅដល់។

-ការរៀបចំឯកសារស្របច្បាប់សម្រាប់ពលករចូលទៅធ្វើការងារនៅក្នុងប្រទេសទទួល ដោយត្រូវជួយពលករដោយមិនយកកម្រៃ ក្នុងការរៀបចំ និងស្នើសុំឯកសារផ្លូវការនានា ដូចជាការធ្វើលិខិតឆ្លងដែន ការជួយឲ្យពលករចុះកិច្ចសន្យាការងារជាមួយនិយោជក ការស្នើសុំការអនុញ្ញាតធ្វើការងារតាមកិច្ចសន្យានៅប្រទេសទទួល ការស្នើសុំទិដ្ឋាការចូលទៅធ្វើការ ការទិញសំបុត្រមធ្យោបាយធ្វើដំណើរ ឬការរៀបចំផ្តល់សេវាធ្វើដំណើរពីព្រះរាជាណាចក្រកម្ពុជាទៅកន្លែងធ្វើការ។

-ការជូនដំណើរ និងការដាក់ឲ្យពលករធ្វើការត្រឹមត្រូវតាមកិច្ចសន្យាការងារ ដែលរួមមានការជូនពលករទៅដល់ច្រកចេញអន្តរជាតិនៃព្រះរាជាណាចក្រកម្ពុជា ការជូនពលករទៅដល់កន្លែងធ្វើការ និងការដាក់ឲ្យពលករធ្វើការដោយត្រឹមត្រូវតាមកិច្ចសន្យា។

-ការតាមឃ្លាំមើល ការផ្តល់សេវានានាទៅតាមការចាំបាច់ និងការដោះស្រាយរាល់បញ្ហានានា ដែលកើតឡើងដោយពលករនិងចំពោះពលករ នៅក្នុងរយៈពេលពលករធ្វើការងារ និងស្នាក់នៅក្នុងប្រទេសទទួលរហូតដល់ចប់កិច្ចសន្យាការងារ និងធ្វើមាតុភូមិនិវត្តន៍។

-ការផ្តល់សេវាទំនាក់ទំនងជាប្រក្រតីរវាងពលករ និងគ្រួសាររបស់ពលករ ដូចជាការសាកសួរសុខទុក្ខ ការជូនដំណឹងផ្សេងៗ ការផ្ញើរបស់របរសំខាន់ៗ ឬការផ្ញើប្រាក់ជាដើម។

-ការរៀបចំសម្រាប់ការបញ្ចប់កិច្ចសន្យា និងការជូនដំណើរពលករមកមាតុប្រទេសវិញ ដូចជាការជូនដំណឹងអំពីការចប់កិច្ចសន្យា ការពិនិត្យនិងទូទាត់ប្រាក់កម្រៃរបស់ពលករ ការចាត់ចែងការបញ្ជូនប្រាក់មកមាតុប្រទេស ការចាត់ចែងឲ្យពលករវិលត្រឡប់មកមាតុប្រទេសវិញដោយសុវត្ថិភាព និងការចាត់ចែងការចុះឈ្មោះពលករពេលមកដល់មាតុប្រទេស។

-រាល់សេវាដែលផ្តល់ជូនពលករ ភាគីទីភ្នាក់ងារជ្រើសរើសឯកជនត្រូវយកចិត្តទុកដាក់ជាពិសេសចំពោះពលករជាស្ត្រី។

-ជាមួយគ្នានេះ  ការណែនាំតម្រង់ទិសពលករមុនពេលចេញដំណើរត្រូវអនុវត្តស្របទៅតាមកម្មវិធី (Curriculum) ដែលក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានកំណត់។

៥- **ទីភ្នាក់ងារជ្រើសរើសឯកជនៈ** សំដៅយកជនទាំងឡាយដូចខាងក្រោមៈ

-ម្ចាស់ភាគហ៊ុនរបស់ក្រុមហ៊ុនឯកជនណាមួយ  ដែលត្រូវបានទទួលស្គាល់ជាផ្លូវការជាទីភ្នាក់ងារជ្រើសរើសឯកជន  ដែលកំពុងធ្វើសកម្មភាពនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងដែលបានចុះកិច្ចសន្យាជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

-ជនទាំងឡាយណា  ដែលត្រូវបានទីភ្នាក់ងារជ្រើសរើសឯកជនកំណត់ឲ្យទទួលខុសត្រូវលើការងារទាំងមូលរបស់ក្រុមហ៊ុន  ឬមួយផ្នែកណារបស់ក្រុមហ៊ុន  ដែលមានការងារច្រើនក្រុមបញ្ចូលគ្នា  ហើយមានសិទ្ធិសម្រេចលើការងារទាំងនោះដោយផ្ទាល់ ដូចជា អគ្គនាយកទីភ្នាក់ងារជ្រើសរើសឯកជន នាយកប្រតិបត្តិផ្នែកនីមួយៗ ប្រធានមជ្ឈមណ្ឌលណែនាំតម្រង់ទិសនីមួយៗជាដើម។

៦- **ភ្នាក់ងារជ្រើសរើស**

ភ្នាក់ងារជ្រើសរើសសំដៅយកកម្មករនិយោជិតទាំងឡាយណារបស់ទីភ្នាក់ងារជ្រើសរើសឯកជន ដែលត្រូវបានពិនិត្យ និងចេញប័ណ្ណសំគាល់ខ្លួន (Pass) ដោយអគ្គនាយកដ្ឋានការងារនៃក្រសួងការងារ  និងបណ្តុះបណ្តាលវិជ្ជាជីវៈ  សម្រាប់ធ្វើការជ្រើសរើសពលករទេសន្តរប្រវេសន៍ សម្រាប់សាមីទីភ្នាក់ងារជ្រើសរើសឯកជននីមួយៗ។